DEPARTMENT OF Education STATE OF MAINE

# មាត្រដ្ឋានកំណត់ភាពត្រឹមត្រូវ/គោលការណ៍ណែនាំចំពោះសេវាកម្មទំនាក់ទំនងដោយការនិយាយ-ភាសានៅក្នុង

## មាត្រដ្ឋានកំណត់ភាពត្រឹមត្រូវនៃភាសា

*<u>និយមន័យ</u>* **: ភាពអន់ខ្សោយនៃភាសា :** ការផ្លាស់ប្តូរណាមួយនៅក្នុងសមាសភាពភាសាខាងក្រោមមួយ ឬច្រើនដែលត្រូវបានអង្កេតនៅខាងក្រៅលំដាប់ដែលអនុញ្ញាតចំពោះសមត្ថភាពនៃការធ្វើទំនាក់ទំនងរបស់បុគ្គលម្នាក់ៗ និង មិនទាក់ទងទៅនឹងគ្រាមភាសា ឬ សាវតាភាសា/វប្បធម៌ ។ ភាពអន់ខ្សោយភាសាមានផលប៉ះពាល់អវិជ្ជមានដល់លទ្ធផលសិក្សារបស់សិស្ស ដែលត្រូវបានឆ្លុះបញ្ចាំងដោយការទំនាក់ទំនងទៅវិញទៅមកក្នុងសង្គមរបស់វា អាកប្បកិរិយា ការអភិវឌ្ឍន៍ផ្លូវចិត្ត ការសិក្សាវិជ្ជាជីវៈ ការទំនាក់ទំនង និង/ឬ ការចូលរួមសកម្មភាពទាំងឡាយនៅក្នុងថ្នាក់រៀន ក៏ដូចជាលទ្ធផលនៃការសិក្សាផងដែរ ។ សមាសភាពទាំងនេះអាចរួមមាន ទម្រង់នៃភាសា (សូរស័ព្ទសាស្ត្រ រូបសាស្ត្រ និង វាកសម្ព័ន្ធ) ផ្នែកខាងក្នុងនៃភាសា (វាក្យស័ព្ទ អត្ថន័យ) និង/ឬ ការប្រើប្រាស់មុខងារនៃភាសា (ការសិក្សាពីរបៀបប្រើភាសានៅក្នុងសង្គម) ។ (មិនត្រូវបានដាក់តាមលំដាប់ទេ)

| | | |
|---|---|---|
| អង្គចងចាំនៃការស្តាប់សម្លេង | ភាពងាយយល់នៃការនិយាយផ្ទាល់មាត់ | ភាពងាយយល់នៃការនិយាយក្នុងកម្រិតអាចសន្ទនាគ្នាបាន |
| ការយកចិត្តទុកដាក់នៃការស្តាប់សម្លេង | ការផ្លាស់ប្តូរពាក្យនៃការនិយាយផ្ទាល់មាត់ | ភាពទាក់ទង និង សភាពកើតឡើងឯកឯងនៃភាសា |
| ការប្រកាន់នៃការស្តាប់សម្លេង | ភាពប្រែប្រួលនៃការនិយាយផ្ទាល់មាត់ | ទំនាក់ទំនងអកម្ម ចន្លោះ កាល និង/ឬការប្រៀបធៀប |
| ការកំណត់លំដាប់នៃការស្តាប់សម្លេង | វាក្យសម្ព័ន្ធ (វេយ្យាករណ៍) | វាក្យស័ព្ទ/ទស្សនៈទាន |

| | <u>គ្មានបញ្ហាជាក់ស្តែង</u> | <u>ខ្សោយ</u> | <u>មធ្យម</u> | <u>ខ្លាំង</u> |
|---|---|---|---|---|
| **ការពិពណ៌នានៃភាសា** | ជំនាញភាសាសមស្របតាមអាយុ | | | |
| **ការវាយតម្លៃធម្មតា** | *<1.0 ការប្រែប្រួលតាមបទដ្ឋានក្រោមពិន្ទុតាមបទដ្ឋានជាមធ្យម ។<br>*ផលចែក ឬ ពិន្ទុតាមបទដ្ឋាននៃភាសាស្មើ 86 ឬ លើសនេះ ។<br>*ភាគរយទី 16 ឬ លើសនេះ | *<1.0 ទៅ 1.5 ការប្រែប្រួលតាមបទដ្ឋានក្រោមពិន្ទុតាមបទដ្ឋានជាមធ្យម ។<br>*ផលចែក ឬ ពិន្ទុតាមបទដ្ឋាននៃភាសាពី 78-85 ។<br>* ភាគរយទី 7-15 | *<1.5 ទៅ 2 ការប្រែប្រួលតាមបទដ្ឋាននៅក្រោមពិន្ទុតាមបទដ្ឋានជាមធ្យម ។<br>*ផលចែក ឬ ពិន្ទុតាមបទដ្ឋាននៃភាសាពី 70-77 ។<br>* ភាគរយទី 2-6 | *<1.5 ទៅ 2 ការប្រែប្រួលតាមបទដ្ឋាននៅក្រោមពិន្ទុតាមបទដ្ឋានជាមធ្យម ។<br>*ផលចែក ឬ ពិន្ទុតាមបទដ្ឋាននៃភាសាស្មើ ឬក្រោម 70 ។<br>* ភាគរយទី 2 ឬ ក្រោមនេះ |
| **ការវាយតម្លៃក្រៅផ្លូវការ**<br>__រចនាសម្ព័ន្ធ<br>__ផ្នែកខាងក្នុង<br>__ការប្រើប្រាស់ និង/ឬ<br>__ដំណើរការនៃការស្តាប់ | ជំនាញភាសារបស់សិស្ស ស្ថិតនៅក្នុងលំដាប់ប្រើភាសាដែលរំពឹងទុករបស់វាផ្អែកលើឧបករណ៍វាយតម្លៃក្រៅផ្លូវការ ។ | ការវាយតម្លៃក្រៅផ្លូវការបង្ហាញពីកង្វះខាតក្នុងការប្រើភាសា | ការវាយតម្លៃក្រៅផ្លូវការបង្ហាញពីកង្វះខាតក្នុងការប្រើភាសា ដែល*ជាធម្មតា* រារាំងក្នុងការទំនាក់ទំនង ។ | ការវាយតម្លៃក្រៅផ្លូវការបង្ហាញថា កូនសិស្សមានជំនាញភាសាតាមមុខងារ *មានកំណត់* ។ ទំនាក់ទំនងគឺជាកិច្ចប្រឹងប្រែងមួយ ។ សិស្សមិននិយាយស្តី និងសមត្ថភាពយល់ដឹង មិនត្រូវបានដឹងប្រាកដ (ឧទាហរណ៍ គំនិតខុសប្លែកពីធម្មតា TBI, HI) ។ |
| **ផលប៉ះពាល់លើការទំនាក់ទំនង** | មិនរារាំងដល់ការទំនាក់ទំនងទេ ។ | មានការរារាំង*តិចតួចបំផុត*ក្នុងការទំនាក់ទំនង | រារាំងក្នុងការទំនាក់ទំនង | រារាំង*យ៉ាងខ្លាំង*ក្នុង និង/ឬទប់ស្កាត់ការទំនាក់ទំនង |
| **ផលប៉ះពាល់លើការអប់រំ** | ការទទួលបានជំនាញសិក្សាមូលដ្ឋាន សង្គម និង/ឬ ជំនាញវិជ្ជាជីវៈ មិនមានផលប៉ះពាល់ទេ ។ | ការទទួលបានជំនាញសិក្សាមូលដ្ឋាន សង្គម និង/ឬ ជំនាញវិជ្ជាជីវៈ *អាច*មានផលប៉ះពាល់ ។ | ការទទួលបានជំនាញសិក្សាមូលដ្ឋាន សង្គម និង/ឬ ជំនាញវិជ្ជាជីវៈ *ជាធម្មតា* មានផលប៉ះពាល់ ។ | ការទទួលបានជំនាញសិក្សាមូលដ្ឋាន សង្គម និង/ឬ ជំនាញ វិជ្ជាជីវៈ *មានភាពអន់ខ្សោយ* ។ |

# មាត្រាដ្ឋានកំណត់ភាពត្រឹមត្រូវនៃការបញ្ចេញសម្លេង

➢ នៅអាយុ 7 ឆ្នាំ ការរីកចម្រើននៃសូរស័ព្ទរបស់សិស្សមានលក្ខណៈពេញលេញ និង មានស្ថេរភាព (Hodson, 1991) ។

*និយមន័យ :* **ភាពអន់ខ្សោយនៃការបញ្ចេញសម្លេង :** ការបញ្ចេញសម្លេងនិយាយខុសពីធម្មតារួមមាន : ការជំនួសពាក្យ ការលុបពាក្យ ដំណើរខុសពីសម្លេងដើម ឬ ការបន្ថែមសម្លេងនិយាយមិនត្រូវនឹងអាយុរបស់សិស្ស ឬ សាវតាភាសានៃវប្បធម៌ និងមិនទាក់ទងជាមួយនឹងគ្រាមភាសា ។

| | គ្មានបញ្ហាជាក់ស្តែង | ខ្សោយ | មធ្យម | ខ្លាំង |
|---|---|---|---|---|
| **ការពិព័ណ៌នានៃការបញ្ចេញសម្លេង** | គ្មានកំហុសក្នុងការបញ្ចេញសម្លេង ឬ ការបញ្ចេញសម្លេងកាន់ល្អ ។ | *កំហុសក្នុងការបញ្ចេញសម្លេងងាយស្តាប់យល់បាន ប៉ុន្តែគួរឱ្យកត់សំគាល់ ។<br>*កំហុសរួមមានប្រភេទទូទៅនៃការជំនួស និង/ឬ ដំណើរខុសពីសម្លេងដើម ។ | *មានកំហុសក្នុងការបញ្ចេញសម្លេងកាន់តែច្រើន ។ ភាពងាយស្តាប់យល់ច្បាស់ មានការពិបាកសម្រាប់អ្នកស្តាប់ដែលមិនសូវស្និទ្ធស្នាល ។<br>*ការប្រើប្រាស់លើសប្រមាណ (40% ឬ លើសនេះ) នៃដំណើរការជំនួស ឬ លុប ដែលមិនសមស្របតាមអាយុ ។ | *មានកំហុសការបញ្ចេញសម្លេងជាច្រើន ។ ការនិយាយជាញឹកញាប់ពិបាកយល់ ចំពោះអ្នកស្តាប់ភាគច្រើន ។<br>*ការប្រើប្រាស់លើសប្រមាណ (40% ឬ លើសនេះ) នៃ ដំណើរការជំនួស ឬ លុប ឬ ដំណើរការប្លែកដែលមិនសមស្របតាមអាយុ ។ |
| **ការវាយតម្លៃធម្មតា** | | *មិនមានកំហុសក្នុងការបញ្ចេញសម្លេង ច្រើនជាង 2 នៅខាងក្រៅគោលការណ៍ណែនាំរីកចម្រើន ។ សិស្សអាចណែនាំឱ្យកែកំហុសក្នុងការបញ្ចេញសម្លេង ។<br>* ភាគរយទី 7-15 លើរង្វាស់តាមបទដ្ឋាន ។<br>* 1 ទៅ 1.5 SD ក្រោមមធ្យម ។ | *ការជំនួសពាក្យ និង ដំណើរខុសពី សម្លេងដើម និង ការលុបពាក្យមួយ ចំនួនអាចកើតឡើង ។ អាចមានការណែនាំមានកំណត់ ឱ្យកែកំហុសការបញ្ចេញសម្លេង ។<br>* ភាគរយទី 2-6 លើរង្វាស់តាមបទដ្ឋាន ។<br>* 1.5 ទៅ 2 SD ក្រោមមធ្យម ។ | *ការប្រែប្រួលមានចាប់ពីការជំនួស ពាក្យដ៏ច្រើនសទ្ទឹកសទ្ទាប់ និង ការលុបពាក្យជាច្រើន រហូតដល់ការលុបពាក្យដ៏ច្រើនសទ្ទឹកសទ្ទាប់។<br>*ចំនួនកំណត់នៃថ្នាក់បញ្ចេញសម្លេង ត្រូវបានបង្ហាញច្បាស់ជាក់ស្តែងនៅក្នុងគំរូភាសា-និយាយ ។ ការកំណត់លំដាប់ព្យញ្ជនៈជាទូទៅនៅខ្វះខាត ។<br>* ភាគរយ <2 លើរង្វាស់តាមបទដ្ឋាន ។<br>* ការប្រែប្រួលតាមបទដ្ឋាន 2 ឬ លើសនេះ ។ |
| **ការវាយតម្លៃក្រៅផ្លូវការ** | | ភាពងាយយល់អាចស្តាប់ 80% នៃរយៈពេលនៅក្នុងការនិយាយទំនាក់ទំនងគ្នា ។ | ភាពងាយយល់អាចស្តាប់បាន 50% ទៅ80% នៃរយៈពេលនៅក្នុងការនិយាយទំនាក់ទំនងគ្នា ។ | ភាពងាយយល់អាចស្តាប់បាន <50% នៃរយៈពេលនៅក្នុងការនិយាយទំនាក់ទំនងគ្នា ។ |
| **ផលប៉ះពាល់លើការទំនាក់ទំនង** | | សិស្សអាចជួបប្រទះនូវផលលំបាកមួយចំនួននៅក្នុងការបង្ហាញពីអារម្មណ៍ និង/ឬ ការយល់ដឹង ។ អ្នកផ្សេងទៀតយល់ពីសារនិយាយរបស់សិស្ស ។ | សិស្សអាចជួបប្រទះការលំបាកមួយចំនួននៅក្នុងការបង្ហាញពីអារម្មណ៍ និង/ឬ ការយល់ដឹង ។ សារនិយាយរបស់សិស្ស *ភាគច្រើន* ត្រូវបានយល់ដោយអ្នកផ្សេងទៀត ។ | *សិស្សមានការបង្ហាញពីអារម្មណ៍ និង /ឬ ការយល់ដឹងតាមមុខងារមានកំណត់ ។* ជាញឹកញាប់អ្នកផ្សេងទៀតមិនយល់ពីសារនិយាយរបស់សិស្សទេ ។<br>* ជាញឹកញាប់ភ្ជាប់ជាមួយដោយបញ្ហាសូរស័ព្ទ ។ |
| **ផលប៉ះពាល់លើការអប់រំ** | | ការទទួលបានជំនាញសិក្សាមូលដ្ឋាន សង្គម និង/ឬ វិជ្ជាជីវៈ *អាច*មានផលប៉ះពាល់ ។ | ការទទួលបានជំនាញសិក្សាមូលដ្ឋាន សង្គម និង/ឬ វិជ្ជាជីវៈ *ជាធម្មតា* មានផលប៉ះពាល់ ។ | ការទទួលបានជំនាញសិក្សាមូលដ្ឋាន សង្គម និង/ឬ វិជ្ជាជីវៈ *មានភាពអន់ខ្សោយ* ។ |

# មាត្រដ្ឋានកំណត់ភាពត្រឹមត្រូវនៃសម្លេង

- នៅពេលសិស្សម្នាក់បង្ហាញឱ្យឃើញថាមានការអន់ខ្សោយនៃសម្លេង សិស្សនោះនឹងត្រូវណែនាំឱ្យធ្វើការព្យាបាល ។

*និយមន័យ :* **ភាពអន់ខ្សោយនៃសម្លេងនិយាយ :** ភាពអន់ខ្សោយនៃសម្លេងគឺជាអវត្តមាន ឬ ភាពខុសពីធម្មតានៃសម្លេងដែលត្រូវបានកំណត់លក្ខណៈដោយ : ការចាប់ផ្តើម/រយៈពេលសម្លេងខុសពីធម្មតា គុណភាពសូរសៀង សូរសម្លេង សម្លេងខ្លាំង និង/ឬ សម្លេងខ្ទរតាមអាយុ ភេទ ឬ ស្ថានភាពនិយាយ ។

-

| | គ្មានបញ្ហាជាក់ស្តែង | ខ្សោយ | មធ្យម | ខ្លាំង |
|---|---|---|---|---|
| **ការពិពណ៌នានៃសម្លេង** | សូរសម្លេង គុណភាព អាំងតង់ស៊ីតេ អត្រា និង សម្លេងខ្ទរខុសពីធម្មតា ។ | ភាពខុសគ្នាដែលគួរឱ្យកត់សំគាល់ អាចមិនត្រូវជាមួយនឹងសូរសម្លេង គុណភាព អាំងតង់ស៊ីតេ អត្រា និង សម្លេងខ្ទរខុសពីធម្មតា ។ | ភាពខុសគ្នាដែលគួរឱ្យកត់សំគាល់យូរអង្វែង ត្រូវបានសំគាល់នៅក្នុងគុណភាពនៃសម្លេង (ភាពតានតឹង សម្លេងខ្ទរ) សូរសម្លេង អាំងតង់ស៊ីតេ ឬ អត្រា ។ | *ភាពខុសគ្នាដ៏លើសលុបបំផុតគួរឱ្យកត់សំគាល់ ត្រូវបានសំគាល់នៅក្នុងគុណភាពនៃសម្លេង (ភាពតានតឹង សម្លេងខ្ទរ ) សូរសម្លេង អាំងតង់ស៊ីតេ ឬ អត្រា។ |
| **ការវាយតម្លៃក្រៅផ្លូវការ** | | ភាពខុសគ្នានៃសម្លេងរួមមាន សម្លេងស្អកសម្លេងចុងច្រមុះ សម្លេងដើមក សូរសម្លេង ឬ អាំងតង់ស៊ីតេ មិនសមស្របតាមអាយុរបស់សិស្ស គឺជាការព្រួយបារម្ភណ៍*តិចតួចបំផុត* ចំពោះឳពុកម្តាយ គ្រូ សិស្ស ឬ គ្រូពេទ្យ ។ | *ភាពខុសគ្នានៃសម្លេង *គឺជាការព្រួយបារម្ភណ៍* ចំពោះឳពុកម្តាយ គ្រូ សិស្ស ឬ គ្រូពេទ្យ ។<br>*សម្លេង*មិនសមស្រប*តាមអាយុ និងភេទរបស់សិស្ស ។ | ភាពខុសគ្នានៃសម្លេង គឺជា*ការព្រួយបារម្ភណ៍* ចំពោះឳពុកម្តាយ គ្រូ សិស្ស ឬ គ្រូពេទ្យ ។ សម្លេងខុសពីអាយុ និង ភេទរបស់សិស្សដាច់ ។ |
| **ផលប៉ះពាល់លើការទំនាក់ទំនង** | | *ភាពខុសគ្នានៃសម្លេង *មិនខ្លាំងល្មមអាចរារាំង* ដល់ការទំនាក់ទំនងឡើយ ។<br>*ចំណេះដឹងរបស់សិស្សអាចមានផលប៉ះពាល់ដល់ការទំនាក់ទំនង ។ | ភាពខុសគ្នានៃសម្លេងអាចរារាំងដល់ការទំនាក់ទំនង និង ធ្វើភាពងាយស្តាប់អាចយល់បានថយចុះ ឬ ទាំងពីរតែម្តង ។ | ភាពខុសគ្នានៃសម្លេង ធ្វើឱ្យការទំនាក់ទំនង និង ភាពងាយស្តាប់អាចយល់បានថយចុះ ឬទាំងពីរតែម្តង ។ |
| **ផលប៉ះពាល់លើការអប់រំ** | | *សម្លេង*កម្រ*ធ្វើឱ្យអ្នកស្តាប់ពិបាកស្តាប់សារ ។<br>*មានផលប៉ះពាល់តិចតួចចំពោះដំណើរការទំនាក់ទំនងសង្គម ផ្លូវចិត្ត និង/ឬ ការសិក្សា ។<br>*មានប្រតិកម្មពីអ្នកស្តាប់ និង/ឬ អ្នកនិយាយតិចតួច ដោយកត់សំគាល់ពីអ្នកស្តាប់ដែលមានភាពស្និទ្ធស្នាលពីរនាក់ ។ | *សម្លេងនិយាយ*ពិត*ជាធ្វើឱ្យអ្នកស្តាប់ពិបាកស្តាប់សារ ។<br>*មានប្រតិកម្ម និង ការព្រួយបារម្ភណ៍មធ្យម ដោយកត់សំគាល់ពីអ្នកស្តាប់ដែលមានភាពស្និទ្ធស្នាលពីរនាក់ ។<br>*រារាំងដល់ដំណើរការទំនាក់ទំនង សង្គម ផ្លូវចិត្ត និង/ឬ ការសិក្សា ។ | *សម្លេងនិយាយ*ពិត*ជាធ្វើឱ្យអ្នកស្តាប់ពិបាកស្តាប់សារ ។<br>*ការជៀសវាងស្ថានភាពនិយាយគ្នា អាចត្រូវបានអង្កេតឃើញ ។<br>*កំណត់យ៉ាងខ្លាំងចំពោះ ដំណើរការទំនាក់ទំនងក្នុងសង្គម ផ្លូវចិត្ត និង /ឬ ការសិក្សា ដោយសមត្ថភាពក្នុងការទំនាក់ទំនងសមស្របមានកំណត់ ។ |

## មាត្រាដ្ឋានកំណត់ភាពត្រឹមត្រូវនៃភាពស្ទាត់ជំនាញ

*<u>និយមន័យ :</u>* **ភាពអន់ខ្សោយនៃភាពស្ទាត់ជំនាញ :** ភាពអន់ខ្សោយនៃភាពស្ទាត់ជំនាញគឺជាលំហូរខុសពីធម្មតានៃការនិយាយស្តីផ្ទាល់មាត់ ដែលត្រូវបានកំណត់លក្ខណៈដោយអត្រាភាពស្ទាត់ជំនាញ និង ចង្វាក់ថយចុះ ដែលអាចមានមកជាមួយដោយអាកប្បកិរិយាខិតខំប្រឹងប្រែងផងដែរ ។

| | <u>គ្មានបញ្ហាជាក់ស្តែង</u> | <u>ខ្សោយ</u> | <u>មធ្យម</u> | <u>ខ្លាំង</u> |
|---|---|---|---|---|
| **ការពិព័ណ៌នានៃភាពស្ទាត់ជំនាញ** | ភាពស្ទាត់ជំនាញនៃការនិយាយ មិនទាក់ទាញចំណាប់អារម្មណ៍ចំពោះសិស្សឡើយ ។ | *ក្នុងពាក្យនិយាយ 100 ពាក្យ មាន 3 ទៅ 5% នៃពាក្យសរុប ដែលនិយាយត្រដិត ។<br>*មិនមានលក្ខណៈបន្ទាប់បន្សំ ការរួញរា និង អាកប្បកិរិយាគេចវេស ។<br>*ការនិយាយមានភាពស្ទាត់ជំនាញ គ្រប់បាំងបាន ។ | *ក្នុងពាក្យនិយាយ 100 ពាក្យ មាន 6-10% នៃពាក្យសរុប ដែលនិយាយត្រដិត ។<br>*លក្ខណៈបន្ទាប់បន្សំ ការរួញរា និង អាកប្បកិរិយាគេចវេស *អាច*លេចឡើង ។ | *ក្នុងពាក្យនិយាយ 100 ពាក្យមាន 11% ឬលើសនេះនៃពាក្យសរុប ដែលនិយាយត្រដិត ។<br>*លក្ខណៈបន្ទាប់បន្សំ ការរួញរា និង អាកប្បកិរិយាគេចវេស *មាន*លេចឡើង ជាពិសេសគួរកត់សំគាល់ និង លំបាក ។ |
| **ការវាយតម្លៃក្រៅផ្លូវការ** | | ភាពមិនស្ទាត់ជំនាញបណ្តោះអាសន្ន ត្រូវបានអង្កេតឃើញនៅក្នុងស្ថានភាពជាក់លាក់ ។ | ភាពមិនស្ទាត់ជំនាញជាញឹកញាប់ ត្រូវបានអង្កេតឃើញនៅក្នុងស្ថានភាពជាច្រើន ។ | អាកប្បកិរិយានៃភាពមិនស្ទាត់ជំនាញដែលជាទម្លាប់ ត្រូវបានអង្កេតឃើញនៅក្នុងស្ថានភាពភាគច្រើន ។ |
| **ផលប៉ះពាល់លើការទំនាក់ទំនង** | | សិស្សអាចដឹងពីអាកប្បកិរិយាមិនស្ទាត់ជំនាញ ។ | សិស្សអាចបង្ហាញពីការយល់ដឹងពីអាកប្បកិរិយាមិនស្ទាត់ជំនាញ ។ | *សិស្សជាធម្មតាបង្ហាញការយល់ដឹងពីអាកប្បកិរិយាមិនស្ទាត់ជំនាញ ។<br>*ការគេចវេសនៃស្ថានភាពនិយាយ ត្រូវបានអង្កេតឃើញ ។ |
| **ផលប៉ះពាល់លើការអប់រំ** | | *មានប្រតិកម្មពីអ្នកស្តាប់តិចបំផុត ។<br>***មានផលប៉ះពាល់ទៅលើការអប់រំតិចបំផុត ។ | មានប្រតិកម្មមួយចំនួនពីអ្នកស្តាប់ និង វារារាំងដល់ដំណើរការអប់រំ ។ | *កំណត់យ៉ាងខ្លាំងចំពោះដំណើរការអប់រំ ។<br>*សិស្សអាចធ្វើរបាយការណ៍ លំហាត់ផ្ទាល់មាត់ និង អានខ្សោយ ។<br>*សិស្សអាចដកចេញពីសកម្មភាពសិក្សាជាក្រុម ។<br>*សិស្សអាចត្រូវបានចំអក មិនអើពើ ឬ ដកចេញពីក្រុមលេងល្បែងកម្សាន្តផ្សេងៗ ឬ សកម្មភាពជាក្រុម ។ |

ប្រភពឯកសារ :
Arkansas Severity Ratings for Language
ASHA Guidelines for the Roles and Responsibilities of the School-Based Speech-Language Pathologist
ASHA, IDEA and Your Caseload, 1999
Howard County Public School, Maryland, “Communication Rating Scales, Service Delivery Model, and Dismissal Criteria for Speech-Language Service
School Union #98, “Guidelines for Speech Language Communication Services, 1997”
MSAD #59, “Language Severity Rating Scale”